# រឿងមហាភារតយុទ្ធ នៅក្នុងសិល្បៈទស្សនីយភាពខ្មែរ

រឿងពីរដែលសំខាន់និងជាវណ្ណកម្មនៅក្នុងសិល្បៈទស្សនីយភាពខ្មែរ គឺរឿងរាមកេរ្តិ៍ និងរឿងមហាភារតយុទ្ធ ជារឿងដែលមានប្រភពចេញមកពីប្រទេសឥណ្ឌា និងមានអាយុកាលក្នុងចំណោមចាស់ជាងគេនៅលើពិភពលោក។

ប្រវត្តិនិងអភិវឌ្ឍន៍នៃរឿងមហាភារតយុទ្ធ គឺវែងឆ្ងាយនិងស្មុកស្មាញខ្លាំងណាស់ ដែលកើតឡើងរវាងភពពីរ អតីតនិងបច្ចុប្បន្ន បច្ចុប្បន្ននិងអនាគត ក្នុងភពស្រមើស្រមៃ និងភពពិត ច្បាប់កម្មផល និងហេតុនិងផល ជាដើម។ មហាភារតយុទ្ធក៏ជារឿងមួយពេញលេញនិងស៊ីជម្រៅបំផុត ដែលគេអះអាងនៅក្នុងជំពូកទី១ថា «អ្វីដែលមាននៅទីនេះ ក៏អាចមាននៅកន្លែងឯទៀត ហើយអ្វីដែលគ្មាននៅទីនេះ ក៏មិនអាចមាននៅកន្លែងឯទៀតឡើយ»។[១]

រឿងមហាភារតយុទ្ធ ត្រូវបានគេសរសេរនិងនិយាយតៗគ្នាជាភាសាសំស្ក្រឹតក៏ដូចជាគ្រាមភាសាទូទាំងតំបន់អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍។ ឯព្រឹត្តិការណ៍និងសាច់រឿងមហាភារតយុទ្ធ ត្រូវបានគេយកមកអភិវឌ្ឍបកស្រាយបង្ហាញនៅលើសិលាចារឹក ចម្លាក់ គំនូរ ក៏ដូចជាសិល្បៈទស្សនីយភាពនានា រួមទាំងរបាំ ល្ខោន និងភាពយន្តផងដែរ។

បើយើងពិនិត្យមើលពីគ្រប់ជ្រុងជ្រោយ គឺមិនត្រឹមតែរឿងសង្គ្រាមនោះទេ យើងឃើញថា រឿងនេះលាតត្រដាងបង្ហាញពីកត្តាកម្មផលនិងហេតុផលដែលមានឥទ្ធិពលមកលើជីវិតអតីតកាល បច្ចុប្បន្នកាល និងអនាគតកាលទៀតផង។ ចំណុចសំខាន់គឺរឿងមហាភារតយុទ្ធសង្កត់ធ្ងន់ទៅលើគោលបំណងទាំងបួននៃមនុស្សជាតិគឺ៖ គោលបំណងកម្មផល ធម៌ និងនិព្វាន និងទំនាក់ទំនងរវាងបុគ្គលនិងសង្គម ដែលជាបំណងដើមរបស់អ្នកនិពន្ធ វ្យាសៈ (Vyasa)។

«មហាភារតៈ» មានន័យថា «រឿងដ៏អស្ចារ្យនៃត្រកូលក្សត្រភារតៈ»។[២] «ភារតៈ» ក៏ជាពាក្យមួយដែលជនជាតិឥណ្ឌាប្រើដើម្បីសម្គាល់សញ្ជាតិឥណ្ឌា ដូច្នេះគឺមានន័យថា «រឿង

---

[១] Fitzgerald 2007: 2

[២] Fitzgerald 2007: 1; Nelson 2007: 1

ដ៏អស្ចារ្យនៃប្រទេសឥណ្ឌា»។[៣] មានប្រភពខ្លះអះអាងថា ជារឿងដែលធំជាងគេរបស់មនុស្សជាតិ។[៤]

តាមប្រពៃណី អ្នកកាន់សាសនាហិន្ឌូ សន្មតថារឿងមហាភារតយុទ្ធត្រូវបាននិពន្ធឡើងដោយឥសី វ្យាសៈ ដោយបានសូត្រឱ្យ ព្រះគណេស ជាអ្នកសរសេរ។ រឿងនេះជារឿងដ៏វែង តាំងតែពីយុគសម័យវេទ ប្រមាណសតវត្សទី៥ មុនគ្រឹស្តសករាជ និងនៅក្នុងទម្រង់ចុងក្រោយនាយុគសម័យហ្គុបតា សតវត្សទី៤ នៃគ្រឹស្តសករាជ។[៥]

រឿងមហាភារតយុទ្ធ មាន៧៤,០០០ របះ ឬ ១,៨ លានពាក្យ ប្រវែងបីដងវែងជាងគម្ពីរប៊ីប ៨ដងវែងជាងរឿង អ៊ីលីយ៉ាដនិងអូឌីស៊ីបញ្ចូលគ្នា របស់លោក ហូមើរ ប្រមាណ ៤ដងវែងជាងរឿងរាមកេរ្តិ៍ ហើយដែលមានប្រវែងខ្លីជាងតែរឿង ស្តេចហ្គែហ្សឺ របស់ទីបេ និងរឿង ម៉ាណាស របស់គៀហ្គីហ្សតែប៉ុណ្ណោះ។[៦]

នៅក្នុងបណ្តាប្រទេសក្នុងតំបន់អាស៊ាន យើងសង្កេតឃើញថា ប្រទេសឥណ្ឌូណេស៊ីជាពិសេស និយមយករឿងមហាភារតយុទ្ធជាមូលដ្ឋានដើម្បីបង្កើតជាស្នាដៃសិល្បៈទស្សនីយភាពរបស់គេ។ ចុះហេតុអ្វីបានជាខ្មែរយើង មិនសូវបានយករឿងមហាភារតយុទ្ធមកតម្លើងជាសិល្បៈទស្សនីយភាព? បើតាមការសង្កេតនិងពិនិត្យរបស់ខ្ញុំទៅលើរឿងនេះ គឺដោយសារកត្តាមួយចំនួន ដូចជាកត្តាផ្នត់គំនិតវាយតម្លៃជាមុន (Preconceived idea) នយោបាយត្រឹមត្រូវ (Political correctness) ចំណុចរសើប ត្រង់សង្គ្រាមនិងជម្លោះរវាងគ្រួសារ បងប្អូន គ្មានរឿងស្នេហាច្រើន មិនជាទីចាប់អារម្មណ៍ ទាក់ទាញ ដូចជារឿងរាមកេរ្តិ៍ របាំទេពមនោរម្យ (ស្រីនិងប្រុស) (Dualism) ឈុតសុវណ្ណមច្ឆា (មច្ឆានិងហនុមាន) រាមឥសូរ មណីមេខលា (យក្សនិងទេពអប្សរ) ជាដើម។

យ៉ាងណាមិញ នាពេលបច្ចុប្បន្ន ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងជំរុញលើកទឹកចិត្តឲ្យសិល្បករសិល្បការិនីនិងលោក

---

[៣] Nelson 2007: 1

[៤] Tokunaga 1994: 1

[៥] Tokunaga 1994: 1; Fitzgerald 2007: 1

[៦] *Mahābhārata* 2007: 1; Nelson 2007: 1; Fitzgerald 2007: 11

គ្រូអ្នកគ្រូគតម្ទើងស្នាដៃសិល្បៈទស្សនីយភាព ធ្វើការសិក្សាស្រាវជ្រាវលើរឿងមហាភារតយុទ្ធ ដើម្បីរំលេចឡើងបន្ថែម ជាពិសេសពីលើរឿងរាមកេរ្តិ៍និងរឿងឯទៀតដែលមាននៅក្នុងបញ្ជីសារពើភ័ណ្ឌសិល្បៈទស្សនីយភាពខ្មែរបច្ចុប្បន្ន។

## ឯកសារពិគ្រោះ


ជួន ណាត.

(១៩៦៧). *វចនានុក្រមខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

ឈឹម ក្រសេម (ឧកញ៉ាទេពពិទូរ).

(២០០៧). *រឿងមហាភារតយុទ្ធ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

ទូច គឹមស្រ៊ាង.

(២០១៩). *សទ្ទានុក្រមខ្មែរបាលីសំស្ក្រឹត*. ភ្នំពេញ: មូលនិធិអៀង (អៀង សុផាក់)។

ធន់ ហ៊ិន (អ្នកប្រែសម្រួល).

(២០១០). *រឿងមហាភារតៈ*. ភ្នំពេញ: ធន់ ហ៊ិន។

ធន់ ហ៊ិន.

(២០០៥). *បទានុក្រមនៃរឿងរាមាយណៈ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

ធន់ ហ៊ិន.

(២០០៣). *រាជសព្ទក្នុងភាសាខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

Fitzgerald, James L.

(1999). *The Story of the Mahabharata*. Knoxville, TN: University of Tennessee Press.

________.

(2007). *The Mahabharata: The Great Epic of India*. Chicago: University of Chicago Press.

*Mahabharata*.

(2007). Encyclopedia Britannica.

Nelson, Richard (Trans.).

(2007). *The Mahabharata*. Farlex, Inc.

Tokunaga, Muneo.

(1994). *The Mahabharata*. Kyoto: HinduNet, Inc.


អត្ថបទដោយ៖ បណ្ឌិត សំ សំអាង